ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

លេខ ១៦៦ / គ.ជ.ប សសរ.ស
១៥

សេចក្តីសម្រេច
ស្តីពី
គោលការណ៍សមាហរណកម្មមន្ត្រីអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងលេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត នៅក្នុងក្របខណ្ឌមន្ត្រីរាជការនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០២ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០៣ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៥/៣២៧ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៥ ស្តីពីការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៥/៦៤៨ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីរាជការនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញអនុក្រឹត្យលេខ ១០៦ អនក្រ.បក ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- យោងស្មារតីអង្គប្រជុំគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ ២០១៥

សម្រេច

ជំពូកទី១
បទប្បញ្ញត្តិទូទៅ

ប្រការ១.-

សេចក្តីសម្រេចនេះ មានគោលបំណងកំណត់គោលការណ៍សម្រាប់ធ្វើសមាហរណកម្មមន្ត្រីកំពុងបម្រើការងារនៅក្នុងអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) និងលេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត (លធ.ខប) ដើម្បីផ្ទេរបញ្ចូលទៅក្នុងក្របខណ្ឌអ្នករាជការនៃ គ.ជ.ប (អ.គ.ជ.ប) ស្របតាមព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីរាជការនៃ គ.ជ.ប។

ប្រការ២.-

សេចក្តីសម្រេចនេះ មានគោលដៅរៀបចំធ្វើសមាហរណកម្មមន្ត្រីកំពុងបម្រើការងារនៅក្នុងអគ្គលេខាធិការដ្ឋាននៃ គ.ជ.ប និង លធ.ខប ទៅក្នុងក្របខណ្ឌ ឋានន្តរសក្តិ និងថ្នាក់នៃក្របខណ្ឌ អ.គ.ជ.ប។

ប្រការ៣.-

សេចក្តីសម្រេចនេះ មានវិសាលភាពអនុវត្តចំពោះមន្ត្រីកំពុងបម្រើការងារនៅក្នុងអគ្គលេខាធិការដ្ឋាននៃ គ.ជ.ប និង លធ.ខប និងសម្រាប់តែការធ្វើសមាហរណកម្មមន្ត្រីរាជការរបស់ គ.ជ.ប តែម្តងប៉ុណ្ណោះ។

ជំពូកទី២
គោលការណ៍សមាហរណកម្មតាមមុខតំណែង

ប្រការ៤.-

មន្ត្រីកំពុងបម្រើការងារនៅក្នុងអគ្គលេខាធិការដ្ឋាននៃ គ.ជ.ប និង លធ.ខប ដែលត្រូវធ្វើសមាហរណកម្មផ្ទេរបញ្ចូលទៅក្នុងក្របខណ្ឌមន្ត្រីបោះឆ្នោតជាន់ខ្ពស់ "ប្រភេទក្របខណ្ឌ ក" គឺជាមន្ត្រីទាំងឡាយណាដែលកំពុងកាន់មុខតំណែងពិតប្រាកដ នៅក្នុងអង្គការលេខនៃរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាននៃ គ.ជ.ប និង លធ.ខប មាន៖

ក- ឋានន្តរសក្តិ ឧត្តមមន្ត្រី

- អគ្គលេខាធិការ
- អគ្គលេខាធិការរង
- និងមន្ត្រីដែលមានមុខតំណែងឯទៀត ដែលមានឋានៈស្មើនឹងមុខតំណែងខាងលើ។

ខ- ឋានន្តរសក្តិ វរមន្ត្រី

- ប្រធាននាយកដ្ឋាន
- និងមន្ត្រីដែលមានមុខតំណែងឯទៀត ដែលមានឋានៈស្មើនឹងមុខតំណែងខាងលើ។

គ- ឋានន្តរសក្តិ អនុមន្ត្រី

- អនុប្រធាននាយកដ្ឋាន
- ប្រធានលេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត (លធ.ខប)
- និងមន្ត្រីដែលមានមុខតំណែងឯទៀត ដែលមានឋានៈស្មើនឹងមុខតំណែងខាងលើ។

ប្រការ៥ .-

ការធ្វើសមាហរណកម្មមន្ត្រីកំពុងបម្រើការងារនៅក្នុងអគ្គលេខាធិការដ្ឋាននៃ គ.ជ.ប និង លធ.ខប ត្រូវផ្ទេរបញ្ចូលទៅក្នុងថ្នាក់នៃឋានន្តរសក្តិនីមួយៗរបស់ក្របខណ្ឌមន្ត្រីបោះឆ្នោតជាន់ខ្ពស់ ត្រូវគិតតាមចំនួនឆ្នាំបម្រើការងាររដ្ឋ ដូចមានកំណត់ក្នុងតារាងឧបសម្ព័ន្ធទី១ **ក** តារាងឧបសម្ព័ន្ធទី១ **ខ** និងតារាងឧបសម្ព័ន្ធទី១ **គ** នៃសេចក្តីសម្រេចនេះ។

ប្រការ៦ .-

ការធ្វើសមាហរណកម្មមន្ត្រីកំពុងបម្រើការងារនៅក្នុងអគ្គលេខាធិការដ្ឋាននៃ គ.ជ.ប និង លធ.ខប ផ្ទេរបញ្ចូលទៅក្នុងក្របខណ្ឌមន្ត្រីបោះឆ្នោតជាន់ខ្ពស់ ត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ តាមសំណើរបស់ គ.ជ.ប។

ប្រការ៧ .-

មន្ត្រីកំពុងបម្រើការងារនៅក្នុងអគ្គលេខាធិការដ្ឋាននៃ គ.ជ.ប និង លធ.ខប ដែលត្រូវធ្វើសមាហរណកម្មផ្ទេរបញ្ចូលទៅក្នុងក្របខណ្ឌមន្ត្រីបោះឆ្នោតមធ្យម "ប្រភេទក្របខណ្ឌ ខ" គឺជាមន្ត្រីទាំងឡាយណាដែលកំពុងកាន់មុខតំណែងពិតប្រាកដ នៅក្នុងអង្គការលេខនៃរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាននៃ គ.ជ.ប និង លធ.ខប មានៈ

ក- ឋានន្តរសក្តិ នាយក្រមការ

- ប្រធានការិយាល័យ
- អនុប្រធានលេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត (លធ.ខប)
- និងមន្ត្រីដែលមានមុខតំណែងឯទៀត ដែលមានឋានៈស្មើនឹងមុខតំណែងខាងលើ។

ខ- ឋានន្តរសក្តិ ក្រមការដើមខ្សែ

- អនុប្រធានការិយាល័យ
- និងមន្ត្រីដែលមានមុខតំណែងឯទៀត ដែលមានឋានៈស្មើនឹងមុខតំណែងខាងលើ។

គ- ឋានន្តរសក្តិ ក្រមការ

- មន្ត្រីជំនាញ
- និងមន្ត្រីដែលមានមុខតំណែងឯទៀត ដែលមានឋានៈស្មើនឹងមុខតំណែងខាងលើ។

ប្រការ៨ ._

ការធ្វើសមាហរណកម្មមន្ត្រីកំពុងបម្រើការងារនៅក្នុងអគ្គលេខាធិការដ្ឋាននៃ គ.ជ.ប និង លធ.ឧប ត្រូវផ្ទេរបញ្ចូលទៅក្នុងថ្នាក់នៃឋានន្តរសក្តិនីមួយៗរបស់ក្របខណ្ឌមន្ត្រីបោះឆ្នោតមធ្យម ត្រូវគិតតាមចំនួនឆ្នាំបម្រើការងាររដ្ឋ ដូចមានកំណត់ក្នុងតារាងឧបសម្ព័ន្ធទី២ **ក** តារាងឧបសម្ព័ន្ធទី២ **ខ** និងតារាងឧបសម្ព័ន្ធទី២ **គ** នៃសេចក្តីសម្រេចនេះ។

ប្រការ៩ ._

ការធ្វើសមាហរណកម្មមន្ត្រីកំពុងបម្រើការងារនៅក្នុងអគ្គលេខាធិការដ្ឋាននៃ គ.ជ.ប និង លធ.ឧប ត្រូវផ្ទេរបញ្ចូលទៅក្នុងក្របខណ្ឌមន្ត្រីបោះឆ្នោតមធ្យម ត្រូវធ្វើឡើងដោយសេចក្តីសម្រេចរបស់ គ.ជ.ប។

ជំពូកទី៣
គោលការណ៍សមាហរណកម្មតាមអតីតភាពការងារ

ប្រការ១០ ._

មន្ត្រីកំពុងបម្រើការងារនៅក្នុងអគ្គលេខាធិការដ្ឋាននៃ គ.ជ.ប និង លធ.ឧប ក្រៅពីមន្ត្រីដែលបានធ្វើសមាហរណកម្មទៅតាមមុខតំណែងខាងលើ ត្រូវធ្វើសមាហរណកម្មផ្ទេរបញ្ចូលទៅក្នុងក្របខណ្ឌមន្ត្រីបោះឆ្នោតបឋម "ប្រភេទក្របខណ្ឌ គ" ដោយគិតតាមអតីតភាពការងារ។

ប្រការ១១ ._

មន្ត្រីកំពុងបម្រើការងារនៅក្នុងអគ្គលេខាធិការដ្ឋាននៃ គ.ជ.ប និង លធ.ឧប ដែលបានធ្វើសមាហរណកម្មផ្ទេរបញ្ចូលទៅក្នុងក្របខណ្ឌមន្ត្រីបោះឆ្នោតបឋម ដែលមានអតីតភាពការងារ ចាប់ពី៣ (បី) ឆ្នាំឡើងទៅ ត្រូវរៀបចំផ្ទេរបញ្ចូលទៅក្នុងថ្នាក់ ដោយគិតរយៈពេល៣ (បី) ឆ្នាំ សម្រាប់មួយថ្នាក់។

ប្រការ១២ ._

ការធ្វើសមាហរណកម្មមន្ត្រីកំពុងបម្រើការងារនៅក្នុងអគ្គលេខាធិការដ្ឋាននៃ គ.ជ.ប និង លធ.ឧប ត្រូវផ្ទេរបញ្ចូលទៅក្នុងក្របខណ្ឌមន្ត្រីបោះឆ្នោតបឋម ត្រូវធ្វើឡើងដោយសេចក្តីសម្រេចរបស់ គ.ជ.ប។

ជំពូកទី៤
បទប្បញ្ញត្តិដោយឡែក

ប្រការ១៣ .-

មន្ត្រីកំពុងបម្រើការងារនៅក្នុងអគ្គលេខាធិការដ្ឋាននៃ គ.ជ.ប និង លធ.ខប ដែលកំពុងកាន់មុខតំណែងដូចមានចែងក្នុងប្រការ៧ ហើយមានបរិញ្ញាបត្រ ឬមានសញ្ញាបត្រសមមូល ត្រូវធ្វើសមាហរណកម្មផ្ទេរបញ្ចូលទៅក្នុងឋានន្តរសក្តិអនុមន្ត្រីនៃក្របខណ្ឌមន្ត្រីបោះឆ្នោតជាន់ខ្ពស់។

មន្ត្រីដែលកំពុងបម្រើការងារនៅក្នុងអគ្គលេខាធិការដ្ឋាននៃ គ.ជ.ប និង លធ.ខប ដែលមានសញ្ញាបត្រខ្ពស់ជាងមុខតំណែងរបស់ខ្លួន នៅពេលធ្វើសមាហរណកម្មផ្ទេរបញ្ចូលទៅក្នុងក្របខណ្ឌថ្មី ត្រូវគិតទៅតាមកម្រិតសញ្ញាបត្រ។

សមាជិកខុទ្ទកាល័យ និងសមាជិកក្រុមជំនួយការងាររបស់ថ្នាក់ដឹកនាំ គ.ជ.ប ត្រូវបានធ្វើសមាហរណកម្មផ្ទេរបញ្ចូលទៅក្នុងក្របខណ្ឌតាមមុខតំណែងដែលមានឋានៈស្មើ ឬតាមកម្រិតសញ្ញាបត្រ សម្រាប់ការធ្វើសមាហរណកម្មលើកដំបូងនេះតែប៉ុណ្ណោះ។ ដោយឡែកមុខងារនៃសមាជិកណាដែលត្រូវបានតែងតាំងក្រោយការធ្វើសមាហរណកម្មនេះ ជាមុខងារសម្រាប់តែមួយរយៈប៉ុណ្ណោះ។ ហេតុនេះ នៅពេលត្រូវបានបញ្ចប់ពីការងារ សមាជិកណាដែលពីមុនគ្មានលក្ខណសម្បត្តិដើមជាមន្ត្រីក្របខណ្ឌ ពុំអាចទាមទារលក្ខណសម្បត្តិនេះបានដោយយោលទៅលើការតែងតាំងដោយ គ.ជ.ប នោះឡើយ។ ផ្ទុយទៅវិញសមាជិកណាដែលមានលក្ខណសម្បត្តិជាមន្ត្រីក្របខណ្ឌរួចមកហើយ ត្រូវរក្សាទុកដដែលនូវលក្ខណសម្បត្តិនេះ ព្រមទាំងអតីតភាពរបស់ខ្លួនក្នុងស្ថាប័នដើម។

ប្រការ១៤ .-

មន្ត្រីកំពុងបម្រើការងារនៅក្នុងអគ្គលេខាធិការដ្ឋាននៃ គ.ជ.ប និង លធ.ខប ដែលកំពុងស្ថិតក្នុងក្របខណ្ឌជាមន្ត្រីរាជការក្របខណ្ឌនីតិប្បញ្ញត្តិ ក្របខណ្ឌនីតិប្រតិបត្តិ ក្របខណ្ឌតុលាការ និងក្របខណ្ឌពិសេសផ្សេងទៀត ព្រមទាំងក្របខណ្ឌនគរបាលជាតិ និងក្របខណ្ឌកងយោធពលខេមរភូមិន្ទ ហើយមានបំណងបន្តបម្រើការងារជា អ.គ.ជ.ប ត្រូវផ្ទេរក្របខណ្ឌចេញពីក្រសួង ស្ថាប័នដើមចូលមកបម្រើការងារនៅអគ្គលេខាធិការដ្ឋាននៃ គ.ជ.ប និង លធ.ខប តាមនីតិវិធីជាធរមាន ក្នុងរយៈពេល៣០ (សាមសិប) ថ្ងៃយ៉ាងយូរ មុនថ្ងៃធ្វើសមាហរណកម្ម។ ក្នុងករណីធ្វើបែបបទមិនទាន់ សាមីជននោះ អាចថតចម្លងពាក្យស្នើសុំផ្ទេរក្របខណ្ឌចេញពីក្រសួង ស្ថាប័នដើម ដែលមានហត្ថលេខារបស់ថ្នាក់លើមួយថ្នាក់យ៉ាងតិច រួចដាក់ជូន គ.ជ.ប ជាបណ្តោះអាសន្ន។

ប្រសិនបើក្របខណ្ឌ ឋានន្តរសក្តិ និងថ្នាក់របស់សាមីជននៅក្រសួង ស្ថាប័នដើមខ្ពស់ជាងក្របខណ្ឌ ឋានន្តរសក្តិ និងថ្នាក់ដែលត្រូវធ្វើសមាហរណកម្មផ្ទេរបញ្ចូលទៅក្នុងក្របខណ្ឌ អ.គ.ជ.ប ត្រូវបានរៀបចំឱ្យស្មើនឹងក្របខណ្ឌ ឋានន្តរសក្តិ និងថ្នាក់របស់សាមីជននៅក្រសួង ស្ថាប័នដើម។

ក្នុងករណីដែលមន្ត្រីទាំងឡាយណាមិនមកបម្រើការងារជា អ.គ.ជ.ប សាមីជនត្រូវដាក់ពាក្យសុំលាឈប់ពីការងារ ចេញពីអគ្គលេខាធិការដ្ឋាននៃ គ.ជ.ប ឱ្យបាន៧ (ប្រាំពីរ) ថ្ងៃយ៉ាងតិច នៅមុនថ្ងៃធ្វើសមាហរណកម្ម។

ប្រការ១៥ ..

ក្នុងករណីរកឃើញ អ.គ.ជ.ប ណា ដែលមានក្របខណ្ឌលើសពីមួយកន្លែង សាមីជននោះ នឹងត្រូវលុបឈ្មោះចេញពីក្របខណ្ឌ អ.គ.ជ.ប ជាស្វ័យប្រវត្តិ និងទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។

ប្រការ១៦ ..

អ.គ.ជ.ប ដែលមានអាយុលើសពីការកំណត់ ដូចមានចែងក្នុងមាត្រា៥៥ នៃព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីរាជការនៃ គ.ជ.ប អាចដាក់ពាក្យសុំបន្តធ្វើការងារជា អ.គ.ជ.ប ក្នុងរយៈពេល១០ (ដប់) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃធ្វើសមាហរណកម្ម។

គ.ជ.ប ត្រូវសម្រេចលើការស្នើសុំនេះ ក្នុងរយៈពេល៣០ (សាមសិប) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យសុំ។

ប្រការ១៧ ..

ចំពោះ អ.គ.ជ.ប ដែលដល់អាយុចូលនិវត្តន៍ ហើយត្រូវបានកំណត់ដោយ គ.ជ.ប៖

- យល់ព្រមឱ្យបន្តធ្វើការងារ សាមីជនត្រូវបានអនុញ្ញាតឱ្យបន្តការងារដដែល
- មិនយល់ព្រមឱ្យបន្តធ្វើការងារ សាមីជនត្រូវបានដាក់ឱ្យចូលនិវត្តន៍។

ប្រការ១៨ ..

ចំពោះ អ.គ.ជ.ប ដែលបានចូលនិវត្តន៍ហើយពីស្ថាប័នផ្សេង ប៉ុន្តែពុំដែលទទួលបានប្រាក់សោធននិវត្តន៍ ហើយត្រូវបាន គ.ជ.ប៖

- យល់ព្រមឱ្យបន្តធ្វើការងារ សាមីជនត្រូវបានអនុញ្ញាតឱ្យបន្តការងារដដែល
- មិនយល់ព្រមឱ្យបន្តធ្វើការងារ សាមីជនត្រូវដាក់ឱ្យចូលនិវត្តន៍ ដោយទទួលប្រាក់ឧបត្ថម្ភផ្សេងៗ និងប្រាក់សោធននិវត្តន៍តាមគោលការកំណត់។

ប្រការ១៩ ..

ចំពោះ អ.គ.ជ.ប ដែលបានចូលនិវត្តន៍ហើយពីស្ថាប័នផ្សេង និងកំពុងទទួលបានប្រាក់សោធននិវត្តន៍ ហើយត្រូវបាន គ.ជ.ប៖

- អនុញ្ញាតឱ្យបន្តធ្វើការងារ សាមីជនត្រូវបានទទួលប្រាក់បំណាច់មុខងារ ប្រាក់បំណាច់បោះឆ្នោត និងប្រាក់វិភាជន៍គ្រួសារ តែមិនបានទទួលប្រាក់បៀវត្សមូលដ្ឋានទេ
- មិនអនុញ្ញាតឱ្យបន្តធ្វើការងារ សាមីជនត្រូវបានលុបឈ្មោះចេញពី អ.គ.ជ.ប និងមិនបានទទួលនូវប្រាក់ឧបត្ថម្ភអ្វីឡើយ។

ប្រការ២០.-

គ.ជ.ប ត្រូវបង្កើតគណៈកម្មការសមាហរណកម្មដើម្បីរៀបចំធ្វើសមាហរណកម្មមន្ត្រីដែលកំពុងបម្រើការងារនៅក្នុងអគ្គលេខាធិការដ្ឋាននៃ គ.ជ.ប និង លធ.ខប ទៅតាមគោលការណ៍ខាងលើ។ ការធ្វើសមាហរណកម្មត្រូវសម្រេចដោយ គ.ជ.ប បន្ទាប់ពីមានការផ្តល់យោបល់ពីគណៈកម្មការសមាហរណកម្ម។ គណៈកម្មការសមាហរណកម្មនេះ មានសមាសភាពដូចខាងក្រោម៖

១- តំណាង គ.ជ.ប	ប្រធាន
២- អគ្គលេខាធិការ ឬតំណាង	អនុប្រធាន
៣- គ្រប់ប្រធាននាយកដ្ឋានចំណុះឱ្យ អគ្គលេខាធិការដ្ឋាន ឬតំណាង	សមាជិក
៤- ប្រធានការិយាល័យបុគ្គលិក	សមាជិក។

ប្រការ២១.-

នីតិវិធីណែនាំការអនុវត្តគោលការណ៍ធ្វើសមាហរណកម្មនេះ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ គ.ជ.ប។

ជំពូកទី៥
អវសានប្បញ្ញត្តិ

ប្រការ២២.-

គណៈកម្មការសមាហរណកម្ម និងអគ្គលេខាធិការនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ [illegible] ឆ្នាំ២០១៥

ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ស៊ិក ប៊ុនហុក

កន្លែងទទួល៖

-គ្រប់ក្រសួង ស្ថាប័ន

-ដូចប្រការ២២

-ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធទី១ "ក" នៃសេចក្តីសម្រេចលេខ ចុះថ្ងៃទី ខែ ឆ្នាំ២០១៥

គោលការណ៍នៃការធ្វើសមាហរណកម្មមន្ត្រីដែលកំពុងបម្រើការងារ
នៅក្នុងអគ្គលេខាធិការដ្ឋាននៃ គ.ជ.ប និង លធ.ឧប ទៅក្នុងក្របខណ្ឌ អ.គ.ជ.ប

មន្ត្រីរាជការក្នុងឋានន្តរសក្តិឧត្តមមន្ត្រីនៃក្របខណ្ឌមន្ត្រីបោះឆ្នោតជាន់ខ្ពស់

មុខតំណែងដែលត្រូវធ្វើសមាហរណកម្មបញ្ចូលទៅក្នុងឋានន្តរសក្តិឧត្តមមន្ត្រី មាន៖

- អគ្គលេខាធិការ
- អគ្គលេខាធិការរង
- និងមន្ត្រីដែលមានមុខតំណែងឯទៀត ដែលមានឋានៈស្មើនឹងមុខតំណែងខាងលើ។

ឋានន្តរសក្តិឧត្តមមន្ត្រី	អតីតភាពបម្រើការងាររដ្ឋ	ផ្សេងៗ
ថ្នាក់លេខ១		គិតចាប់ពីថ្ងៃចូលធ្វើការដំបូង
ថ្នាក់លេខ២		
ថ្នាក់លេខ៣	ពី២៥ ឆ្នាំ ឡើងទៅ	
ថ្នាក់លេខ៤	ពី២២ ឆ្នាំ ដល់២៥ ឆ្នាំ	
ថ្នាក់លេខ៥	ពី១៩ ឆ្នាំ ដល់២២ ឆ្នាំ	
ថ្នាក់លេខ៦	ពី១៦ ឆ្នាំ ដល់១៩ ឆ្នាំ	

<u>កំណត់សម្គាល់៖</u>

- មន្ត្រីកំពុងបម្រើការងារនៅក្នុងអគ្គលេខាធិការដ្ឋាននៃ គ.ជ.ប និង លធ.ឧប ដែលមានអតីតភាពការងារតិចជាង១៦ ឆ្នាំ ក្នុងឋានន្តរសក្តិឧត្តមមន្ត្រី ក៏ត្រូវដាក់ឱ្យស្ថិតក្នុងថ្នាក់លេខ៦ ផងដែរ។

1-6
1-5
1-4
1-3
1-2
1

ឧបសម្ព័ន្ធទី១ "ខ" នៃសេចក្តីសម្រេចលេខ ចុះថ្ងៃទី ខែ ឆ្នាំ២០១៥

គោលការណ៍នៃការធ្វើសមាហរណកម្មមន្ត្រីដែលកំពុងបម្រើការងារ
នៅក្នុងអគ្គលេខាធិការដ្ឋាននៃ គ.ជ.ប និង លធ.ឧប ទៅក្នុងក្របខណ្ឌ អ.គ.ជ.ប

មន្ត្រីរាជការក្នុងឋានន្តរសក្តិវរមន្ត្រីនៃក្របខណ្ឌមន្ត្រីបោះឆ្នោតជាន់ខ្ពស់

មុខតំណែងដែលត្រូវធ្វើសមាហរណកម្មបញ្ចូលទៅក្នុងឋានន្តរសក្តិវរមន្ត្រី មានៈ

- ប្រធាននាយកដ្ឋាន
- និងមន្ត្រីដែលមានមុខតំណែងឯទៀត ដែលមានឋានៈស្មើនឹងមុខតំណែងខាងលើ។

ឋានន្តរសក្តិវរមន្ត្រី	អតីតភាពបម្រើការងាររដ្ឋ	ផ្សេងៗ
ថ្នាក់លេខ១	ពី១៧ ឆ្នាំ ឡើងទៅ	គិតចាប់ពីថ្ងៃចូលធ្វើការដំបូង
ថ្នាក់លេខ២	ពី១៤ ឆ្នាំ ដល់១៧ ឆ្នាំ	
ថ្នាក់លេខ៣	ពី១១ ឆ្នាំ ដល់១៤ ឆ្នាំ	
ថ្នាក់លេខ៤	ពី៨ ឆ្នាំ ដល់១១ ឆ្នាំ	

<u>កំណត់សម្គាល់ៈ</u>

- មន្ត្រីកំពុងបម្រើការងារនៅក្នុងអគ្គលេខាធិការដ្ឋាននៃ គ.ជ.ប និង លធ.ឧប ដែលមានអតីតភាពការងារតិចជាង៨ ឆ្នាំ ក្នុងឋានន្តរសក្តិវរមន្ត្រី ក៏ត្រូវដាក់ឱ្យស្ថិតក្នុងថ្នាក់លេខ៤ ផងដែរ។

2-4 2-5 2-4 2-3 2-2 2-1

ឧបសម្ព័ន្ធទី២ "ក" នៃសេចក្តីសម្រេចលេខ ចុះថ្ងៃទី ខែ ឆ្នាំ២០១៥

គោលការណ៍នៃការធ្វើសមាហរណកម្មមន្ត្រីដែលកំពុងបម្រើការងារ
នៅក្នុងអគ្គលេខាធិការដ្ឋាននៃ គ.ជ.ប និង លធ.ខប ទៅក្នុងក្របខណ្ឌ អ.គ.ជ.ប

មន្ត្រីរាជការក្នុងឋានន្តរសក្តិនាយក្រមការនៃក្របខណ្ឌមន្ត្រីបោះឆ្នោតមធ្យម

មុខតំណែងដែលត្រូវធ្វើសមាហរណកម្មបញ្ចូលទៅក្នុងឋានន្តរសក្តិនាយក្រមការ មានៈ

- ប្រធានការិយាល័យ
- អនុប្រធានលេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត (លធ.ខប)
- និងមន្ត្រីដែលមានមុខតំណែងឯទៀត ដែលមានឋានៈស្មើនឹងមុខតំណែងខាងលើ។

ឋានន្តរសក្តិនាយក្រមការ	អតីតភាពបម្រើការងាររដ្ឋ	ផ្សេងៗ
ថ្នាក់លេខ១		គិតចាប់ពីថ្ងៃចូលធ្វើការដំបូង
ថ្នាក់លេខ២		
ថ្នាក់លេខ៣	ពី២៦ ឆ្នាំ ឡើងទៅ	
ថ្នាក់លេខ៤	ពី២២ ឆ្នាំ ដល់២៥ ឆ្នាំ	
ថ្នាក់លេខ៥	ពី១៩ ឆ្នាំ ដល់២២ ឆ្នាំ	
ថ្នាក់លេខ៦	ពី១៦ ឆ្នាំ ដល់១៩ ឆ្នាំ	

កំណត់សម្គាល់ៈ

- មន្ត្រីកំពុងបម្រើការងារនៅក្នុងអគ្គលេខាធិការដ្ឋាននៃ គ.ជ.ប និង លធ.ខប ដែលមានអតីតភាពការងារតិចជាង១៦ ឆ្នាំ ក្នុងឋានន្តរសក្តិនាយក្រមការ ក៏ត្រូវដាក់ឱ្យស្ថិតក្នុងថ្នាក់លេខ៦ ផងដែរ។

ឧបសម្ព័ន្ធទី១ "គ" នៃសេចក្តីសម្រេចលេខ ចុះថ្ងៃទី ខែ ឆ្នាំ២០១៥

គោលការណ៍នៃការធ្វើសមាហរណកម្មមន្ត្រីដែលកំពុងបម្រើការងារ
នៅក្នុងអគ្គលេខាធិការដ្ឋាននៃ គ.ជ.ប និង លធ.ខប ទៅក្នុងក្របខណ្ឌ អ.គ.ជ.ប

មន្ត្រីរាជការក្នុងឋានន្តរសក្តិអនុមន្ត្រីនៃក្របខណ្ឌមន្ត្រីបោះឆ្នោតជាន់ខ្ពស់

មុខតំណែងដែលត្រូវធ្វើសមាហរណកម្មបញ្ចូលទៅក្នុងឋានន្តរសក្តិអនុមន្ត្រី មានៈ

- អនុប្រធាននាយកដ្ឋាន
- ប្រធានលេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត (លធ.ខប)
- និងមន្ត្រីដែលមានមុខតំណែងឯទៀត ដែលមានឋានៈស្មើនឹងមុខតំណែងខាងលើ។

ឋានន្តរសក្តិអនុមន្ត្រី	អតីតភាពបម្រើការងាររដ្ឋ	ផ្សេងៗ
ថ្នាក់លេខ១	ពី៩ ឆ្នាំឡើងទៅ	គិតចាប់ពីថ្ងៃចូលធ្វើការដំបូង
ថ្នាក់លេខ២	ពី៦ ឆ្នាំ ដល់៩ ឆ្នាំ	
ថ្នាក់លេខ៣	ពី៣ ឆ្នាំ ដល់៦ ឆ្នាំ	
ថ្នាក់លេខ៤	ក្រោម៣ ឆ្នាំ	

ឧបសម្ព័ន្ធទី២ "ខ" នៃសេចក្ដីសម្រេចលេខ ចុះថ្ងៃទី ខែ ឆ្នាំ២០១៥

គោលការណ៍នៃការធ្វើសមាហរណកម្មមន្ត្រីដែលកំពុងបម្រើការងារ

នៅក្នុងអគ្គលេខាធិការដ្ឋាននៃ គ.ជ.ប និង លធ.ខប ទៅក្នុងក្របខណ្ឌ គ.ជ.ប

មន្ត្រីរាជការក្នុងឋានន្តរសក្តិក្រមការដើមខ្សែនៃក្របខណ្ឌមន្ត្រីបោះឆ្នោតមធ្យម

មុខតំណែងដែលត្រូវធ្វើសមាហរណកម្មបញ្ចូលទៅក្នុងឋានន្តរសក្តិក្រមការដើមខ្សែ មាន៖

- អនុប្រធានការិយាល័យ
- និងមន្ត្រីដែលមានមុខតំណែងឯទៀត ដែលមានឋានៈស្មើនឹងមុខតំណែងខាងលើ។

ឋានន្តរសក្តិក្រមការដើមខ្សែ	អតីតភាពបម្រើការងាររដ្ឋ	ផ្សេងៗ
ថ្នាក់លេខ១	ពី១៧ ឆ្នាំឡើងទៅ	គិតចាប់ពីថ្ងៃចូលធ្វើការដំបូង
ថ្នាក់លេខ២	ពី១៤ ឆ្នាំ ដល់១៧ ឆ្នាំ	
ថ្នាក់លេខ៣	ពី១១ ឆ្នាំ ដល់១៤ ឆ្នាំ	
ថ្នាក់លេខ៤	ពី៨ ឆ្នាំ ដល់១១ ឆ្នាំ	

<u>កំណត់សម្គាល់៖</u>

- មន្ត្រីកំពុងបម្រើការងារនៅក្នុងអគ្គលេខាធិការដ្ឋាននៃ គ.ជ.ប និង លធ.ខប ដែលមានអតីតភាពការងារតិចជាង៨ ឆ្នាំ ក្នុងឋានន្តរសក្តិក្រមការដើមខ្សែ ក៏ត្រូវដាក់ឱ្យស្ថិតក្នុងថ្នាក់លេខ៤ ផងដែរ។